**Summary of Kerajaan Malaysia v. Yong Siew Choon- No 01-5-2004 (W) [2005] MYFC 20 (14 October 2005) Court of Appeal**

ពាក្យគន្លឹះ÷ អ្នកទទួលមរតក បញ្ហាច្បាប់ ការបកស្រាយច្បាប់

## ១. អង្គហេតុ

ប្តីរបស់អ្នកប្តឹងឧទ្ធរណ៍ បានបើកក្រុមហ៊ុនវិនិយោគ និងមានអចលនៈទ្រព្យមួយចំនួន។ ក្រោយមកគាត់បានស្លាប់។ ប្រពន្ធ (អ្នកប្តឹង) បានទទួលយល់ព្រមនូវថវិកាមួយចំនួន ជាចំណែកនៃហ៊ុន ព្រមទាំងអចលនៈទ្រព្យពីសពប្តី។ ផ្អែកលើមូលដ្ឋាននេះ រដ្ឋាភិបាលបាន ប្រមូលពន្ធពីប្រពន្ធ លើអចនវត្ថុរបស់ប្តី (estate)។ ប្រពន្ធមិនបានបង់ពន្ធ ហើយនីតិវិធីប្តឹងផ្តល់បានផ្តើមដំណើរការ។ តុលាការជាន់ខ្ពស់ (high court) បានសម្រេចឲ្យគាត់បង់ពន្ធទឹកប្រាកចំនួន 290918 RM។ ប្រពន្ធ បានប្តឹងទៅសាលាឧទ្ធរណ៍ ថា រដ្ឋាភិបាល ធ្វើនេះមិនត្រឹមត្រូវ ដោយសារ គាត់ទទួលលុយនោះ ជាលុយអំណោយ ( *ex gratia* payme nt) មិនជាប់ពន្ធ។

ក្នុងនីតិវិធី មានបញ្ហាផ្លូវច្បាប់មួយដែលត្រូវបានលើកឡើង រដ្ឋាភិបាលបានសម្រេចប្តឹងទៅសាលាឧទ្ធរណ៍ (Court of Appeal) ឲ្យពិចារណាមើលខ្លឹមសារមួយថាតើច្បាប់ (បទបញ្ជាលេខ ១៥វិធាន ៦ក) អនុញ្ញាតឲ្យរដ្ឋាភិបាលប្តឹងបានទេ ក្នុងករណីគ្មាននរណាម្នាក់អាចប្តឹងក្នុងរឿងនេះ។ ចុងចម្លើយ បានអះអាងថា រដ្ឋាភិបាល មិនសិទ្ធិប្តឹងនាងទេ ដោយសារនាង មិនស្ថិតចូលក្នុងប្រភេទនៃអ្នកបន្តមរតកទេ។

## ២. សំអាងហេតុនិងសេចក្តីសម្រេច

ចៅក្រមសាលាឧទ្ធរណ៍ យោងដល់យុត្តិសាស្ត្រ រកឃើញថា តាមច្បាប់ អ្នកទទួលមរតក មិនអាចបដិសេធវិញបានទេ។ បន្ថែមពីលើនេះពាក្យ “executor” ត្រូវបានបកទូលាយ ដោយក្តោបចូលប្រភេទបុគ្គលដូចជាអ្នកប្តឹង។ ពាក់ព័ន្ធនឹងបទបញ្ជា១៥ វិធាន៦ក ចៅក្រមយល់ថា វិធាននេះចែងទូលាយ ទុកច្រកឲ្យមានការប្តឹងទារពន្ធ ដែលខកខានមិនបានបង់ ហើយអាជ្ញាធររដ្ឋក៏មានសិទ្ធិក្នុងការប្តឹងផងដែរ។

ចៅក្រមសាលាឧទ្ធរណ៍ បានពិនិត្យមើលបទប្បញ្ញត្តិពាក់ព័ន្ធ ហើយបានរកឃើញថា ប្រពន្ធគឺជាអ្នកចាត់ចែងទ្រព្យរបស់ប្ដីដែលស្លាប់ ហើយសាលក្រមចេញទាមទារឲ្យគាត់បង់ពន្ធនោះ ត្រឹមត្រូវ។ ជាចុងក្រោយ បណ្ដឹងរបស់រដ្ឋាភិបាល អាចទទួលយកបាន (មានសិទ្ធិប្ដឹងបាន)។

## ៣. ខ្លឹមសារដកស្រង់

*នៅពេល សភាកំណត់អត្ថន័យពាក្យដែលប្រើ និយមន័យនឹងចងដល់តុលាការ ហើយសូម្បីនិយមន័យនេះ មិនត្រូវតាមន័យធម្មតារបស់ពាក្យដែលបានប្រើ។ តុលាការ មិនត្រូវមើលរំលងនូវនិយមន័យក្នុងច្បាប់ទេ ហើយមិនត្រូវដកយកនូវខ្លឹមសារពិតប្រាកដ ផ្សេងពីខ្លឹមសារឯករាជ្យរបស់វា...។ ប្រសិនបើចេតនារបស់សភាមានភាពច្បាស់លាស់ និងគ្មានស្រពេចស្រពិលហើយជាការពិតនេះ វាស្ថិតនៅក្រៅសមត្ថកិច្ចរបស់តុលាការ ក្នុងការកែតម្រូវ ឬកែប្រែនិយមន័យក្នុងប្រការបកស្រាយ។[1]*

## ប្រភពនៃឯកសារ

សម្រាប់ឯកសារទាំងស្រុងសូមចូលទៅមើល÷

http://www.measboralaws.com/images/pdf/verdict/fed1e782a7450775337a06993fcdfd0b.pdf

[1] "When a Legislature defines the language it uses, its definition is binding upon the Court and this is so even though the definition does not coincide with the ordinary meaning of the word used. It is not for the Court to ignore the statutory definition and proceed to try and extract the true meaning of the expression independently of it ( *Nand Rao v Arunachalam*AIR 1940 Mad 385). If the Legislature's intention is clear and unambiguous, it is obviously outside the jurisdiction of the Court to correct or amend the definition in the interpretation clause (*Mordhwaj Singh v State of UP* 24)."


Appellate courts
Federal Court
Court of Appeal
Appellate court and court of first instance
High Court in Malaya
High Court in Sabah and Sarawak
Courts of first instance
Sessions Court
Magistrates' Courts
Court for Children